## ១. សេចក្តីផ្តើម

ជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF) ជាជំងឺបង្កដោយវីរុស Asfivirus ដែលស្ថិតនៅក្នុងអំបូរ/គ្រួសារ Asfarviridae ហើយជាជំងឺឆ្លងជ្រូកធ្ងន់ធ្ងរ ដែលអាចឆ្លងរាលដាលយ៉ាងឆាប់រហ័សនៅលើសត្វជ្រូកគ្រប់ប្រភេទតាមរយៈការចម្លងផ្ទាល់រវាងជ្រូកស្រុក និងជ្រូកស្រុក និងជ្រូកស្រុក និងជ្រូកព្រៃ និងឆ្លងដោយប្រយោលតាមរយៈមនុស្សប៉ះពាល់ជ្រូកឈឺ ឬងាប់ សាច់ជ្រូក សម្ភារៈ និងមធ្យោបាយដឹកជញ្ជូនសត្វជ្រូក និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត។

## ២. ភាពធន់នៃវីរុសបង្កជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅក្នុងផលិតផលសាច់ជ្រូក និងបរិស្ថាន

ពពួកវីរុសបង្កជំងឺប៉េស្តជ្រូកអាហ្វ្រិកនេះវាអាចរស់នៅបានយូរក្នុងសាច់ជ្រូក ផលិតផលសាច់ជ្រូក និងបរិស្ថានសមស្រប ប្រការនេះហើយដែលវាធ្វើឱ្យមានការចម្លងជំងឺនេះពីតំបន់មួយទៅតំបន់ថ្មីមួយទៀត។ ម្យាងទៀតជំងឺនេះ វាឆ្លងរាលដាលធ្ងន់ធ្ងរទៅលើសត្វជ្រូកតាមរយៈការឆ្លងផ្ទាល់ និងដោយប្រយោល ហើយវីរុសនេះអាចរស់នៅជុំវិញបរិស្ថានបានយូរដូចជា:




វីរុសនៃជំងឺនេះ វាអាចរស់នៅក្នុងពពួកសត្វដង្កែទន់បានយូរ ដែលបង្កជាភាពសាំញ៉ាំនៃការចម្លងមេរោគ និងធ្វើឱ្យមានការលំបាកដល់ការលុប់បំបាត់ជំងឺបានទាំងស្រុង ពេលខ្លះយើងអាចចំណាយពេលពី២០ ទៅ ៣០ឆ្នាំ (នៅបណ្តាប្រទេសជឿនលឿនមួយចំនួន)។ ប៉ុន្តែ វីរុសបង្កជំងឺប៉េស្តជ្រូកអាហ្វ្រិកវាបានបង្កជំងឺធ្ងន់ធ្ងរដែលអត្រាឈឺ និងងាប់រហូតដល់ ១០០% ហើយជំងឺនេះគ្មានថ្នាំព្យាបាល និងវ៉ាក់សាំងសម្រាប់ការពារទេ (ចាប់តាំងពីឆ្នាំ១៩០៧មកម្លេះ) នៅអាហ្វ្រិក ប្រទេសកេនញ៉ា។ ហើយក៏ពុំមានភស្តុតាងណាមួយដែលបង្ហាញថា ជំងឺប៉េស្តជ្រូកអាហ្វ្រិកនេះ បានបង្កឱ្យមានបញ្ហាដល់សុខភាពមនុស្សទេ ប៉ុន្តែវាបានធ្វើឱ្យជ្រូកងាប់ បង្កការខាតបង់ដល់អ្នកចិញ្ចឹមជ្រូក និងសេដ្ឋកិច្ចជាតិ។ ហើយអ្វីដែលជាមហន្តរាយធ្ងន់ធ្ងរនោះគឺជំងឺប៉េស្តជ្រូកអាហ្វ្រិកនេះបានកើតដំបូងនៅប្រទេសកម្ពុជា ក្នុងខេត្តរតនៈគីរី ស្រុកអូយ៉ាដាវ នៅឃុំសោមធំ ភូមិសោមកានិញ ដែលស្ថិតក្នុងតំបន់បងប្អូនជនជាតិយើងដែលធ្វើឱ្យសត្វជ្រូកប្រមាណ២.៤០០ក្បាល ត្រូវបានឈឺ ងាប់ និងសម្លាប់ចោល(ក្នុងឆ្នាំ២០១៩)។

## ៣. ប្រភេទសត្វទទួលជំងឺ

នៅតាមតំបន់ព្រំដែនអាស៊ី អឺរុប ជ្រូកព្រៃមានចែធំ ជ្រូកព្រៃយក្ស និងជ្រូកព្រៃ ជាទូទៅជំងឺនេះមិនបង្ហាញរោគសញ្ញាច្បាស់លាស់ទេ ហើយគេគិតថាជ្រូកដែលផ្ទុកវីរុសប៉េស្តនេះបានកើតជាដំបូងគឺនៅអាហ្វ្រិក។




## ៤. ប្រភពបង្កជំងឺ

ជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF) ជាជំងឺបង្កដោយពពួកវីរុស Asfivirus ដែលស្ថិតនៅក្នុងអំបូរ/គ្រួសារ Asfarviridae ហើយវីរុសបង្កជំងឺប៉េស្តជ្រូកអាហ្វ្រិកនេះមានជាង២០សេណូទីប។ វីរុសជំងឺប៉េស្តជ្រូកអាហ្វ្រិក ដែលត្រូវបានចម្លងនៅតំបន់កូកាសគឺប្រភេទ សេណូទីប II។ ចំណែកឯវីរុសដែលកើតមាននៅសាឌីញ៉ាគឺប្រភេទសេណូទីប I។ ហើយវីរុសនៃជំងឺប៉េស្តជ្រូក(ASF) ប្រភេទនីមួយៗមានភាពខុសគ្នាខ្លាំងក្នុងការបង្ករោគពីវីរុសបង្កឱ្យជ្រូកងាប់ច្រើនដល់គ្រាន់តែបង្កឱ្យមានមេរោគនៅក្នុងឈាម។

## ៥. ការចម្លងនៃជំងឺ

ជំងឺប៉េស្តជ្រូកអាហ្វ្រិក អាចឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់រវាងជ្រូកស្រុកនិងជ្រូកស្រុក ជ្រូកស្រុកនិងជ្រូកព្រៃ និងអាចឆ្លងដោយប្រយោលតាមរយៈមនុស្សដែលបានប៉ះពាល់ជ្រូកឈឺ ឬសាច់ជ្រូកដែលផ្ទុកមេរោគ និងតាមសម្ភារៈនិងបរិក្ខារ មធ្យោបាយធ្វើដំណើរ ចំណីសត្វ កាកសំណល់អាហារដែលមានសាច់ជ្រូកមានមេរោគមិនបានចម្អិនល្អ និងឧបករណ៍ប្រើប្រាស់ផ្សេងៗទៀតដែលមានមេរោគជាពិសេសនៅកន្លែងចិញ្ចឹមជ្រូកដែលមានជំងឺ តាមរយៈខ្យល់ តាមផ្លូវដកដង្ហើម តាមរយៈដង្កែទន់(ដែលអាចផ្ទុកវីរុសបង្កជំងឺបេស្តជ្រូកអាហ្វ្រិកបានពី២ទៅ៣ឆ្នាំ) តាមរយៈសត្វល្អិតបឺតឈាម និងតាមរយៈភ្នាក់ងារចម្លងផ្សេងៗទៀត(កណ្តុរ......)។ ការស៊ីចំណីកាកសំណល់ផ្ទះបាយដែលមានផ្ទុកវីរុសបង្កជំងឺប៉េស្តជ្រូកអាហ្វ្រិក។




## ៦. រយៈពេលសំងំនៃវីរុសបង្កជំងឺ

រយៈពេលសំងំរបស់វីរុសបង្កជំងឺនេះចន្លោះពី៥ ទៅ២១ថ្ងៃ បន្ទាប់ពីបានប៉ះផ្ទាល់ជាមួយជ្រូកមានជំងឺ ប៉ុន្តែវាអាចតិចជាង៥ថ្ងៃ បន្ទាប់ពីសត្វដង្កែទន់ខាំ។ ហើយក្នុងករណីស្រួចស្រាវអាចកើតក្នុងអំឡុងពេលពី ៣ ទៅ៧ថ្ងៃ និងចន្លោះ១៥ថ្ងៃ ចំពោះក្ខូត OIE។

## ៧. រោគសញ្ញា

រោគសញ្ញានៃជំងឺប៉េស្តជ្រូកអាហ្វ្រិក គឺស្រដៀងទៅនឹងជំងឺជ្រូកផ្សេងៗទៀតដូចជា ជំងឺប៉េស្តជ្រូក(ស្រដៀងគ្នាពិបាកញែក) ជំងឺសាលម៉ូណេឡាកញ្ច្រិល ជំងឺសារទឹកស្រួចស្រាវ ត្រូវបានគេចែកចេញជា:

**ក. ករណីស្រួចស្រាវ:** សត្វជ្រូកមានសភាពគ្រុនក្តៅខ្លាំង មិនស៊ីចំណីខ្សោយ ដំណើរទ្រេតទ្រោត មានស្នាមអុចៗឈាមនៅលើស្បែក និងសរីរាង្គផ្សេងៗ ស្បែកឡើងពណ៌ស្វាយ ជាពិសេសត្រចៀក កន្ទុយ ជើង ភ្លៅ រាក ទល់លាមក ឬសញ្ញាឈឺពោះ រាកឈាម ពិបាកដកដង្ហើម ហៀរសំបោរ និងសញ្ញាណសរសៃប្រសាទ ជ្រូកផើមជាញឹកញាប់រលូតកូន(ពេលខ្លះរលូតជា សញ្ញាទី១នៃការផ្ទុះជំងឺ) សត្វងាប់អាចកើតឡើងពី៣ ទៅ៧ថ្ងៃ ឬសត្វអាចងាប់ភ្លាមៗ និងមិនមានបង្ហាញស្លាកស្នាម ឬមានស្លាកស្នាមបន្តិចមន្តួច។

**ខ. ករណីមិនស្រួចស្រាវ ឬករណីរាំរ៉ៃ:** ជ្រូកមានសភាពគ្រុនក្តៅ ស្ទោរ មិនសូវលូតលាស់(ក្រិន) បាត់បង់ការស៊ីចំណី មានការថយចុះនៃគោលិកាស និងត្រំបូស៊ីត មានបញ្ហាផ្លូវដង្ហើម ហើមសន្លាក់ ដំបៅ ស្បែកឡើងក្រហម សត្វអាចស្លាប់បានក្នុងសភាពរាំរ៉ៃ មានហូរឈាមក្នុងសរីរាង្គអាចកើតមាន ជ្រូកមានអាការៈរាគ ក្អួតម្តងម្កាល និងអាចបណ្តាលឱ្យងាប់។ ជ្រូកព្រៃ និងជ្រូកព្រៃចៃធំ ជាធម្មតាឆ្លងរោគដោយមិនមានរោគសញ្ញាទេ ប៉ុន្តែជ្រូកអាចងាប់ ឬអាចជា ក្នុងកំឡុងពេល៣ ទៅ៤អាទិត្យ។




## ៨. ការធ្វើរោគវិនិច្ឆ័យ

ជំងឺប៉េស្តជ្រូកអាហ្វ្រិក អាចធ្វើរោគវិនិច្ឆ័យដោយការបណ្តុះវីរុស ហើយវីរុសមិនអាចរកឃើញនៅក្នុងកូនដែលរលូតទេ តែក្នុងករណីនេះ គេត្រូវយកឈាមពីសត្វជ្រូកញី(មេរបស់កូនដែលរលូត) និងសេរ៉ូមសាស្ត្រអាចមានប្រយោជន៍ក្នុងការធ្វើរោគវិនិច្ឆ័យ ជាពិសេសតំបន់មានជំងឺរាតត្បាត។

| PCR | ELISA | រយៈពេលនៃការចម្លង(ប៉ាន់ស្មាន) |
|---|---|---|
| វិជ្ជមាន | អវិជ្ជមាន | តិចជាង១២ថ្ងៃ(សត្វងាប់ ឬយកវត្ថុវិភាគមុន១២ថ្ងៃ) |
| វិជ្ជមាន | វិជ្ជមាន | ច្រើនជាង១២ថ្ងៃ(សត្វងាប់ ឬយកវត្ថុវិភាគមុន១២ថ្ងៃ) |
| អវិជ្ជមាន | វិជ្ជមាន | ច្រើនជាង២៤ថ្ងៃ(សត្វងាប់ ឬយកវត្ថុវិភាគមុន២៤ថ្ងៃ) |

## ៩. ការគ្រប់គ្រង និងការការពារ

**ក. ការគ្រប់គ្រង:** ត្រូវធ្វើអត្តសញ្ញាណកម្មសត្វ និងកត់ត្រានៅកសិដ្ឋានចិញ្ចឹមសត្វ, មិនត្រូវផ្តល់កាកសំណល់ជាចំណីឱ្យសត្វ, រាំងស្កាត់ជ្រូកកុំឱ្យប៉ះពាល់ផ្ទាល់ជាមួយជញ្ជូកដទៃ និងរួមទាំងជ្រូកព្រៃផងដែរ។ ត្រូវកប់/កំទេចចោលឱ្យបានសមស្របនូវកាកសំណល់ចំណីអាហារមានលាយផលិតផលសត្វដែលសង្ស័យថាមានមេរោគជំងឺនេះ, ត្រូវកប់/កំទេចចោលនូវកាកសំណល់សត្វ រួមទាំងលាមក និងសត្វងាប់ដោយសារជំងឺនេះឱ្យសមស្រប, ត្រូវបង្កើតនូវកន្លែងលាងសម្អាតសម្រាប់បុគ្គលិក និងរៀបចំកន្លែងដឹកជញ្ជូនសត្វថ្មីចូលកន្លែងចិញ្ចឹម, ត្រូវធ្វើចត្តាឡីស័កសត្វ ១៤ទៅ៣០ថ្ងៃ, ត្រូវធ្វើការកត់ត្រាការចេញ ចូលសត្វ, ត្រូវកំណត់នូវការយកអាហារចូល និងបរិភោគកន្លែងចិញ្ចឹម, មិនត្រូវបោះចោលនៅកាកសំណល់ផលិតផលសត្វ លាមក សត្វងាប់ នៅតាមទីសាធារណៈ ឬទៅក្នុងប្រភពទឹកឡើយ, ត្រូវធ្វើការត្រួតពិនិត្យ និងធ្វើជីវសុវត្ថិភាពដោយធ្វើកន្លែងសម្លាប់មេរោគនៅច្រកចេញចូលកន្លែងចិញ្ចឹម។



**ខ. ការការពារ ឬការធ្វើជីវសុវត្ថិភាព:** ត្រូវធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹម និងនៅជុំវិញកន្លែងចិញ្ចឹម, មិនត្រូវចិញ្ចឹមសត្វព្រលែងពាសវាលពាសកាល, ពេលចេញ ចូលកន្លែងចិញ្ចឹមត្រូវជ្រលក់ជើង មធ្យោបាយដឹកជញ្ជូន នៅក្នុងប្រព័ន្ធសម្លាប់មេរោគមុនចូលកន្លែងចិញ្ចឹម, ត្រូវបាញ់ថ្នាំសម្លាប់មេរោគលើសម្ភារៈ ឧបករណ៍ប្រើប្រាស់, ជៀសវាងការនាំផលិតផលសាច់ជ្រូកចូល និងឆ្លងកាត់កន្លែងចិញ្ចឹម, ជៀសវាងការប្រើប្រាស់កាកសំណល់ផ្ទះបាយជាចំណីសត្វ, គ្មានការទិញ ឬចរាចរណ៍សត្វជ្រូកពីប្រភពមិនស្គាល់ និងសូមធ្វើការរាយការណ៍ទៅមន្ត្រីជំនាញ ឬអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដែលមានលេខទូរស័ព្ទ ០១២ ២១៤ ៩៧០។



## ១០. ការព្យាបាល

ជំងឺប៉េស្តជ្រូកអាហ្វ្រិក ជាជំងឺបង្កឡើងដោយពពួកវីរុស ដូច្នេះ ជំងឺនេះពុំមានថ្នាំព្យាបាល និងវ៉ាក់សាំងការពារនោះទេ ។

អគ្គនាយកដ្ឋាន
សុខភាពសត្វ និងផលិតកម្មសត្វ

# ជំងឺប៉េស្តជ្រូកអាហ្វ្រិក

( African Swine Fever )



រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម
គាំទ្រដោយ រាជរដ្ឋាភិបាលកម្ពុជា
( ថវិកាកម្មវិធី ឆ្នាំ២០១៩)

ខែកក្កដា ឆ្នាំ២០១៩